ក្រសួងអប់រំយុវជននិងកីឡា

កុមាររៀន
កុមារចេះ
ក ១២៣

# យើងចូលចិត្តទៅ



កម្មវិធីជាតិស្តីពីការសិក្សាកម្រិតថ្នាក់ដំបូង នៃក្រសួងអប់រំ យុវជន និងកីឡា

រឿង ៖ **យើងចូលចិត្តទៅ**
និពន្ធដោយ ៖ **ហ៊ុយ ឆេងរតនា**
វិចិត្ររូបភាពដោយ ៖ **ម៉េត ភារម្យ**

សៀវភៅនេះត្រូវបានបោះពុម្ពផ្សាយក្រោមអាជ្ញាប័ណ្ណ CC BY-SA ។

សៀវភៅនេះត្រូវបានបង្កើតឡើងសម្រាប់កម្មវិធីកុមាររៀនកុមារចេះ ដែលជាកម្មវិធីជាតិស្តីពីការសិក្សាកម្រិតថ្នាក់ដំបូងរបស់ក្រសួងអប់រំ យុវជន និងកីឡា ដោយមានការគាំទ្រពីជំនួយពីពលរដ្ឋអាមេរិក។

ដើម្បីស្វែងរកសៀវភៅនេះនិងសៀវភៅដទៃទៀតសម្រាប់កុមារ លោកអ្នកអាចចូលទៅកាន់ទំព័រហ្វេសប៊ុកកុមាររៀនកុមារចេះ

www.facebook.com/123komar




ឬគេហទំព័រ តោះអាន ឬទាញយកកម្មវិធីបណ្ណាល័យឌីជីថលតោះអាន

Let's Read
www.LetsReadAsia.org

យើងចូលចិត្តទៅជិះទូកមើល
អំពិលអំពែក នៅខេត្តកំពត។





យើងចូលចិត្តទៅមើលព្រៃកោងកាង
នៅខេត្តកោះកុង។



យើងចូលចិត្តទៅហែលទឹកសមុទ្រនៅខេត្តព្រះសីហនុ។



យើងចូលចិត្តទៅឆ្លងស្ពានប្រដឹស
នៅខេត្តកំពង់ចាម។



យើងចូលចិត្តទៅមើលត្រីផ្សោត
នៅខេត្តក្រចេះ។



យើងចូលចិត្តទៅលេងប្រាសាទ
សំបូរព្រៃគុក នៅខេត្តកំពង់ធំ។





យើងចូលចិត្តទៅលេងប្រាសាទអង្គរវត្ត នៅខេត្តសៀមរាប។



យើងចូលចិត្តទៅជិះឡូរី នៅខេត្តបាត់ដំបង។





យើងចូលចិត្តទៅលេងទឹកជ្រោះ ប៊ូស្រា នៅខេត្តមណ្ឌលគិរី។



យើងចូលចិត្តទៅលេងបឹង
យក្សឡោម នៅខេត្តរតនគិរី។



យើងចូលចិត្តទៅលេងវិមានឯករាជ្យ
នៅរាជធានីភ្នំពេញ។





យើងចូលចិត្តដើរលេងកម្សាន្តគ្រប់ខេត្តក្រុង នៅក្នុងប្រទេសកម្ពុជា។



# សំណួរ

១. តើគេជិះទូកមើលអំពិលអំពែកនៅខេត្តណា?

២. តើប្រាសាទអង្គរវត្តស្ថិតនៅក្នុងខេត្តណា?

៣. តើបឹងយក្សឡោមស្ថិតនៅក្នុងខេត្តណា?

៤. តើកូនធ្លាប់ទៅដើរលេងនៅទីណាខ្លះ?
ចូររៀបរាប់។

សិស្សថ្នាក់ទី១ ដែលកំពុងរៀននៅចុងឆ្នាំសិក្សា និង សិស្សថ្នាក់ទី២ ដែលកំពុងរៀននៅដើមឆ្នាំសិក្សា អាចអានសៀវភៅរឿងនេះ ដើម្បីជាការហ្វឹកហាត់អំណានបន្ថែម ដោយមិនចាំបាច់មានអ្នកដទៃជួយឡើយ។ ទោះយ៉ាងណា សិស្សក៏អាចអានសៀវភៅរឿងនេះជាមួយគ្រូបានដែរ ដោយពួកគេអាចមើល និងនិយាយអំពីរូបភាពនៅក្នុងសៀវភៅរឿងនេះហើយអានពាក្យ និងតួអក្សរដែលពួកគេស្គាល់។
ដរាបណាសិស្សចាប់ផ្តើមអានសៀវភៅកាន់តែឆាប់ គឺកាន់តែល្អសម្រាប់ពួកគេ។



កម្មវិធីជាតិស្តីពីការសិក្សាកម្រិតថ្នាក់ដំបូង
នៃក្រសួងអប់រំ យុវជន និងកីឡា

បោះពុម្ពឆ្នាំ ២០២០